I03230

# ប្រវត្តិរូបបដិវត្ត

ផ្ទាល់ខ្លួន :

១.- ឈ្មោះដើម [illegible] ឈ្មោះបដិវត្ត

២.- កើតនៅឆ្នាំកា ១៩៥៦ ។ នៅភូមិវត្តសំពៅ ឃុំតាជេស ស្រុក ១៨ តំបន់ ៣១ ។

៣.- ភេទប្រុស ។ ជាតិខ្មែរ ។

៤.- នៅលីវ ។

៥.- របរកស៊ីមុនចូលបដិវត្ត ធ្វើស្រែជាមូលដ្ឋាន និងចងសន្ទូចបន្ទាប់បន្សំ នៅក្នុងបន្ទុកគ្រួសារ ។

វណ្ណៈភាពដើម កសិករក្រ ។

៦.- របរកស៊ីក្រោយចូលបដិវត្ត នៅក្នុងជួរបដិវត្ត ។

៧.- មុនចូលបដិវត្ត មិនដែលចូលបំរើ អង្គការនយោបាយណាទេ ។

៨.- ចូលបដិវត្តនៅថ្ងៃ ១២ . ៨ . ១៩៧៣ ចូលនៅភូមិបវត្តសំពៅ ឃុំតាជេស ស្រុក ១៨ តំបន់ ៣១ ។

អ្នកនាំចូលឈ្មោះ ពូទៀក - ប្រធានភូមិ - ។

មូលហេតុដែលនាំឲ្យចូលបដិវត្ត :

អង្គការបានណែនាំ មានសតិភារម្យ៉ាងចង់ចូល ដោយមានកំហឹងវណ្ណៈត្រូវគេជិះជាន់ ក៏ចូលធ្វើបដិវត្ត ។

៩.- មិនទាន់ចូលអង្គការ ស.យុវកក ទេ ។

១០- មិនទាន់ចូល បក្ស ទេ ។

១១.- តាំងពីចូលបដិវត្តមកមាននាទីជាយុទ្ធជន ។

១២.- កំរិតវប្បធម៌សង្គមចាស់រៀនថ្នាក់ទី ៩ អត់មានសញ្ញាប័ត្រទេ ។

តាមរបបថ្មី បានយល់ជ្រួតជ្រាប និងភ្ញាក់រលឹកខាងនយោបាយកំរិតខ្ពស់ ។

១៣.- ធ្លាប់រួមជីវភាពក្នុងមូលដ្ឋាន កសិករ យោធា និងមន្ទីរ ។

ដោយយល់ឃើញថា មូលដ្ឋានទាំងអស់នេះ បំរើឱ្យវណ្ណៈ កម្មករ និង កសិករ ។

១៤.- បានរៀនល្បុត្រជាវគ្គ បានជាញឹកញាប់ ។

ជាលាលាបាន ២ ដង :

២.៧៦ រៀននៅវ៉ព្រែកប្រជាំ បងណាតនឹង បងហ៊ុយ ជាអ្នកឧទ្ទេសនាម ។

២៩.៥.៧៧ រៀននៅឈ្នាត អង្គការ ឧទ្ទេសនាម ។

១៥.- បានឆ្លងជីវចលនូវ ៣ ដង និងប្រវត្តិរូប ពីរដង ។

ចំណាយពេលទាំងត្រៀម ទាំងឆ្លង ពី ១០ ទៅ ១៥ ថ្ងៃ ។

១៦.- បានស្គាល់អត្តចរិតរបស់ខ្លួនពីមុន និង គុណសម្បត្តិ និង គុណវិបត្តិមាន :-

គុណសម្បត្តិ - និយាយស្តី- លេងសើចរាបសារ មិនសូវចេះនិយាយច្រើន មិន ផ្លេកផ្លូក ឬក៏ស៊ីផឹកពាលាអាវ៉ាវ៉សវ៉ែរ ទំលាប់ធ្វើការងារអីមួយ ឯចំពោះភារកិច្ចអ្វីដែលបក្ស និង សមូហភាពប្រគល់ឱ្យ គឺធ្វើដោយយកចិត្តទុកដាក់មិនតបត់ ធ្វើដោយរីករាយពេញចិត្ត មិនស្មុគស្មាញ ឬក៏រុញរា ហើយត្រៀមខ្លួនជានិច្ចដើម្បីបំរើបក្ស និង សមូហភាពគ្រប់ពេលវេលា ។

ហើយមិនចេះនិយាយ

គុណវិបត្តិ - ទុយទុយ និយាយមិនស្ទាត់ចេះនឹង វែកញែក × ។ ពេលខ្លះក៏នៅមានបំពេញភារកិច្ចយករួចខ្លួន មិនទាន់ម្ចាស់ការលើការងារខ្ពស់ ~~[illegible]~~ ដំណើរប្រយុទ្ធមិនទាន់ស្រួចស្រាវនៅឡើយ ។ សេរបៀបប៉ះស៊ើយ ។

ចំនុចល្អ : មានការភ្ញាក់រលឹកនយោបាយកម្រិតខ្ពស់ បំពេញភារកិច្ចដោយភ្ញាក់រលឹក ធ្វើដើម្បីបំរើបក្ស និងសមូហភាព ទោះភារកិច្ចតូច-ធំក្តី ហើយបានកំចាត់នៅធាតុបុគ្គលនិយម តួខាងវិភាគការម្មេណ៍មុខមាត់ អំនួត ក្អួតអាង អស់ជាមូលដ្ឋាន និងកំពង់តបន្តកំចាត់ចោលនៅជំហរធ្វើយករួចខ្លួន ឱ្យខំម្ចាស់ការលើការងារទាំងអស់ ខំសំរួចគោលជំហរប្រយុទ្ធឱ្យក្តៅជាប់ស្រប់ភារកិច្ច។

១៧.- អំពីប្រវត្តិសកម្មភាពនយោបាយតាំងពី ្យ

តាំងពីតូចមករស់នៅជួយធ្វើការងារ រកស៊ីធ្វើស្រែ និងជួយឃ្វាលគោឪពុក - ម្តាយ និងរៀនសូត្រ ។

ឆ្នាំ ១៩៦៩យប់ទៀន - នៅក្នុងបន្ទុកគ្រួសារផ្ទែសល ។

១២.៨.៧៣ ចូលបដិវត្ត តាមរយៈឈ្មោះ ពូទៀក - ប្រធានភូមិ - គាត់នាំចូលបដិវត្តនៅភូមិវត្តសំពៅ ឃុំតាជេស ស្រុក១៨ តំបន់ ៣១ ។ នៅមន្ទីរឃុំ- អ្នកទទួលខុសត្រូវឈ្មោះ តាភ្លឹង ។ ធ្វើជាឈ្លប ដោយមាន បងធឿន ជាប្រធាន នឹង បងធឿង ជាអនុ ។

ដើមឆ្នាំ ៧៤ ខ្ញុំមានជំងឺគ្រុនចាញ់នៅដេកពេទ្យនៅមន្ទីរឃុំកន្លះខែ មិនទាន់ជា ឈឺកាន់តែធ្ងន់ដាក់ថ្នាំក៏លែងត្រូវ តាភ្លឹង គណៈឃុំ បច្ចុប្បន្នគណៈស្រុក គាត់ក៏អនុញ្ញាតិឱ្យខ្ញុំទៅព្យាបាលនៅផ្ទះមួយរយៈ ដោយទៅរកថ្នាំខ្មែរវិញ ។ អស់មួយរយៈមកបានធូរបន្តិចហើយ តែវាមិនទាន់ជាដាច់ស្រួលបួលមួយថ្ងៃកាត់មួយថ្ងៃ គោ គាត់~~មិនទាន~~់ឱ្យនៅព្យាបាលទៀតទៅ ។

ខែ ៤ . ៧៥ មកអង្គភាពវិញ ។ ពេលនោះ តាភ្លឹង ចេញទៅទទួលស្រុក នៅតាលិន នឹង តាប៊ិន ទទួលខុសត្រូវឃុំវិញ ។ បន្ទាប់មកតាមរយៈ
ឥ តាលិន នឹង តាប៊ិន ឱ្យខ្ញុំទៀងទៅយោធាស្រុក ១៨ តំបន់ ៣១ ។ នៅយោធាក្រោមការដឹកនាំផ្ទាល់ បងប៉ឿន - បញ្ជាការកងរយ - នឹងបងភឿក ស្នងកងរយ - ក្នុងកងវរៈរបស់ បងភន ។ នៅវាលចារ ឃុំគោកបន្ទាយ កំពង់- ឆ្នាំង ។ បាន ៣ - ៤ ខែតាមរយៈ បងភន ឱ្យទៀងមកកន្លែង តាភ្លឹង - គណៈស្រុក - ហើយគាត់បញ្ជូនមកតំបន់ កន្លែង តាសារុន នឹងតាកណ្ដោ នៅសាលាលេខ ៥ បានប្រហែល ១០ថ្ងៃ បងចាន់ទៅយកមកបឹងជប៉ុន ។ មាននាទីមេក្រុមកុមារ

៩ អ្នកទទួលខុសត្រូវនៅកន្លែងនោះមាន អាម៉ាន ។ ប្រហែលជាខែ ៩.៧៥ អាម៉ាន បាននាំមកសួរចម្លើយនៅ ស.២១ ក្រោមការដឹកនាំរបស់ បងឌុច និង បងចាន់ ។

- ខែ ៤ . ៧៦ មករៀនវាយអង្គុលីលេខ ។
- ខែ ៨ . ៧៧ មកនៅក្រុមសរុបឯកសារ ។

អំពីឪពុក - ម្តាយ

១ - ឪពុកឈ្មោះ រស់ - សុខ អាយុ ៥២ ឆ្នាំ - រស់ -
ម្តាយឈ្មោះ ប៉ិច - ថូ អាយុ ៤៧ ឆ្នាំ - រស់ -
ជាតិខ្មែរ ។ នៅភូមិវត្តលំពែរ ឃុំតាជល ស្រុក១៨ តំបន់ ៣១ ។

២ - ឪពុក របររកស៊ីធ្វើស្រែ និងស៊ីឈ្នួលអារឈើ - អារទាញដោយរណារដៃ - និងរកស៊ីចងល្អប ផង ។ ម្តាយ របររកស៊ីធ្វើស្រែ និងនៅផ្ទះ ។
វណ្ណៈភាព កសិករក្រ ។

៣ - គាត់មិនដែលបំរើអង្គការ ឬ.ប ណាទេ ។ អាកប្បកិរិយាចំពោះបដិវត្ត គាត់ស្រឡាញ់ និងមានជំនឿលើអង្គការ ហើយបានឧបត្ថម្ភជាអង្ករ បាយទឹក ដល់កងទ័ពដែលនៅក្នុងសម័យសង្គ្រាមផង ។ គាត់បានលះបង់កូនចៅឱ្យចូលបំរើបដិវត្ត ។

៤ - ឪពុកម្តាយខ្ញុំ អត់មានឥទ្ធិពលនិងអនុភាពអីខាង ន.ប សេដ្ឋកិច្ច សំភារៈអីមកលើរូបខ្ញុំទេ ។ មានតែមនោសញ្ចេតនាជាធម្មតា ។ ហើយនិងណែនាំឱ្យប្រុងប្រយ័ត្នខ្លួន ។

៥ - ចំពោះរូបខ្ញុំក៏គ្មានឥទ្ធិពលអ្វីទៅលើគាត់ដែរ ។ មានតែនិយាយអំពីជ័យជំនះរបស់កងទ័ព កន្លែងនេះកន្លែងនោះ ដើម្បីឱ្យគាត់រីករាយ ចំពោះជ័យជំនះនេះ ។

## អំពីបងប្អូនបង្កើត

១.- មានបងប្អូនទាំងអស់ ៨នាក់ ប្រុស ៦នាក់ ស្រី ២នាក់ :

១- ឈ្មោះ តុប - ឈយ ចូលបដិវត្តឈ្មោះ អឿន អាយុ២៨ឆ្នាំ ប្រុស ។ លីវ

២- - តុប - សាន អាយុ ២៥ ឆ្នាំ ស្រី មានគ្រួសារហើយ ។

៣- រូបខ្ញុំ

៤- - តុប - ស៊ាន អាយុ ១៩ ឆ្នាំ ប្រុស ។ លីវ ។

៥- - តុប - ស៊ិន អាយុ ១៦ ឆ្នាំ ប្រុស ។ លីវ ។

៦- - តុប - ចំរើន អាយុ ១៣ ឆ្នាំ ប្រុស ។ លីវ ។

៧- - តុប - នាង ហៅ មុំ ១០ ឆ្នាំ ស្រី ។ លីវ ។

៨- -- តុប - ណាត អាយុ ៩ ឆ្នាំ ប្រុស ។ លីវ ។

២.- របររកស៊ី បងទី ១ មុនបដិវត្តធ្វើស្រែនៅក្នុងបន្ទុកគ្រួសារ - ៧០ចូលបដិវត្ត ។ ឮថាស្លាប់បាត់ហើយ ។

របររកស៊ី បងទី២ មុនបដិវត្តធ្វើស្រែ នៅក្នុងបន្ទុកគ្រួសារ ក្រោយមក មានគ្រួសារ របររកស៊ីធ្វើស្រែដែរ វណ្ណៈភាពកណ្តាលថ្នាក់ក្រោម ។

ចំណែកប្អូន ៥ នាក់ មុនបដិវត្តរស់នៅក្នុងបន្ទុកគ្រួសារ ក្រោយបដិវត្តរស់នៅក្នុងសហករណ៍

៣.- និន្នាការនយោបាយ បងប្អូនទាំងអស់នេះមិនដែលចូលបំរើអង្គការនយោបាយណាទេ ។

៤.- បងប្អូនទាំងអស់នេះគ្មានឥទ្ធិពលអនុភាព នឹងជំពាក់ជំពិនអ្វីមកលើរូបខ្ញុំទេ ។

៥.- ចំពោះរូបខ្ញុំក៏គ្មានឥទ្ធិពលអីទៅលើបងប្អូនទាំងអស់នោះដែរ ។

## អំពីមិត្តជិតស្និទ និងមជ្ឈដ្ឋាន

១ .. ចំពោះរូបខ្ញុំគត់មានមិត្តជិតស្និទអី ក្រៅពីក្នុងជួរបដិវត្តទេ ។

ធ្វើនៅថ្ងៃ ៥១ ឆ្នាំ

គុប - ភាព